

# រឿងព្រេងនៃបងប្អូនស្រីវីរៈជនវៀតណាម (ហាយបាជឹងជាឈ្មោះផ្លូវមួយក្នុងទីក្រុងហូជីមិញ)

Let's Read
The Asia Foundation



កាលពីព្រេងនាយ មានដំណើររឿង
មួយដែលបានកើតឡើងជាង 2.000
ឆ្នាំមុន។ ប្រទេសវៀតណាម ដើមឡើយ
រស់នៅជាប្រទេសឯករាជ្យមួយ ដែល
ហៅថារាជវង្សហុង។ បន្ទាប់មក
ប្រទេសហាន់បានរួមគ្នា ជាមួយ
ប្រទេសចិន ហើយបានក្លាយទៅជា
ប្រទេសដ៏ខ្លាំងក្លាហើយវាយប្រហារ
យកវៀតណាមមកកាន់កាប់។ ដោយ
គ្មានអំណាចប្រទេសវៀតណាម ត្រូវ
បានកាន់កាប់ ដោយប្រទេសហាន់។
អំឡុងពេលនោះវៀតណាម ត្រូវបាន
គេហៅថាណាំបៀត។ ប្រទេសហាន់
បានកាន់កាប់និងបែងចែកណាំបៀត



ទៅជាតំបន់។ ក្រោយមកហាន់បាន
ជាន់ឈ្លីលើវប្បធម៌ប្រពៃណីរបស់ណាំ
បៀត ។ ដោយបានដុតកំទេចចោលស្គរ
ប្រពៃណីនៃណាំបៀតដែលធ្វើពីលង្ហិន
វត្ថុមានតម្លៃនៅណាំបៀត មានស្នែង
ដំរីនិងគុជខ្យងព្រមទាំងគ្រាប់ធញ្ញជាតិ
ត្រូវបានដណ្តើមយក។ ការរស់នៅរបស់
ប្រជាជនកាន់តែក្រីក្រនិងទុរគតទៅៗ។



នៅពេលនោះស៊ូឌីន ដែលបានមក ពី
តំបន់ថេស៊ូនៅក្នុងប្រទេសហាន់បាន
គ្រប់គ្រង ចាអូជី ដែលជា តំបន់មួយ
ក្នុងចំណោម តំបន់ទាំង3 នៃណាំបៀត
ប្រជាជនស្អប់ស៊ូឌីងដោយសារគេ
ជាមនុស្សកោងកាច និងលោភលន់
ខ្លាំង។ អំឡុងពេលនោះប្រជាជននៅ
តាមស្រុកទាំង 3 ធ្វើការបះបោរជាហូ
ហែរ ក្រោកឈរឡើងដោយសាមិនអាច
ទ្រាំទៅនិងការជិះជាន់បាន ការងើប
បះបោរនៃ ប្រជាជនក្នុងតំបន់ចាអូជី
បានទទួលជោគជ័យហើយប្រជាជន
បាននៅគ្រាប់ធុញ្ញញជាតិដែលបាត់បង់
ត្រឡប់មកវិញភាពហើយបានរួចផុតពី



ភាពស្រេកឃ្លាន។ ជោគជ័យមានពិត តែមិនអាចបណ្តេញជនជាតិហាន់ដែលខ្លាំងក្លានោះបានដែរ ស៊ូឌីង បានប្រើកងកម្លាំងយោធាជាច្រើនដើម្បីរំខានអ្នកប្រឆាំងនឹង ហើយធ្វើទារុណកម្មដល់ពួកគេ។

នៅសម័យនោះ តំបន់មេរីងហ្សន់ដែលជាអ្នកកាន់កាប់ដីជាច្រើនឈ្មោះរ៉ាក់ចាងរស់នៅ ។ គាត់មានកូនស្រីភ្លោះដ៏ស្រស់ស្អាតដែលមានឈ្មោះថា ”ជឹងចាក់” និង ”ជឹងនី” បងប្អូនស្រីជឹងទាំងពីរ មានទេពកោសល្យផ្នែកវិជ្ជាប្រយុទ្ធ តាំងពីកុមារភាពមកម្ល៉េះ។ ខិតខំរៀនវិជ្ជាប្រយុទ្ធដែលចិត្តចង់



ស្តារយកប្រទេស ខ្លួនដែលប្រទេសហាន់បានដណ្តើមទៅនោះយកមកវិញ ។ ក្រោយមកនាងក៏ធំពេញក្រមុំដ៏ស្រស់ស្អាតនិងថ្លៃថ្នូរដែលទទួលការស្រឡាញ់និងក្តីសង្ឃឹមពីមនុស្សជាច្រើន។



បុរសវ័យក្មេងឈ្មោះធីសាក រស់នៅ
តំបន់ជូជីអេនដែលនៅជាប់និងតំបន់
ម៉ែលរីងហ្សន់។ ធីសាក គឺជាកូនប្រុស
របស់មេបញ្ជាការមួយហើយមានប្រាជ្ញា
និងជំនាញក្នុងវិជ្ជាប្រយុទ្ធ ។ មិនយូ
ប៉ុន្មានធីសាក់ក៏បានជួបនិងបងប្អូន
ត្រកូលជឹងហើយ ហើយមានចិត្តគំនិត
ដូចគ្នាទៅនឹងជឹងចាក់ដែលជាបងស្រី
។ ជឹងចាក់និង ធីសាកបានស្រលាញ់
និងរៀបការជាមួយគ្នារ។ ពួកគេគិតពីរ
រឿងយកប្រទេសជាតិមកវិញធំជាងការ
គិតពីរឿងស្នេហា ពួកគេបានប្រមូល
ផ្តុំគ្នាមនុស្សម្នារហើយបានគ្រោងទុកនូវ
ការបះបោរដ៏ធំមួយ។ ដោយការខិតខំ



បញ្ចុះបញ្ចូលរបស់ពួកគេប្រជាជនក៏
ក្លាយជាធ្លុងមួយ។ ប៉ុន្តែផែនការបះបោរ
នេះត្រូវបានបែកការដល់ស៊ូឌីង។ ស៊ូ
ឌីង បានចាប់ ហើយធ្វើទារុណកម្មធី
សាក់ យ៉ាងឃោឃៅ ។ គំរាមប្រជាជ
នណាំបៀតថានឹងសំលាប់ធីសាក់បើ
មិនបញ្ឈប់សកម្មភាពប្រឆាំង។ ប៉ុន្តែ
ប្រជាជននៅ ណាំបៀតមិនបានភ្លាចរ
អាពីការគំរាមនោះឡើយ។ ទីបំផុត
ធីសាក ត្រូវសម្លាប់យ៉ាងឃោរឃៅ។
———————————— ជឹងចាក់និង
ជឹងនី ទទួលអារម្មណ៍តក់ស្លុតយ៉ាង
ខ្លាំង នៅពេលឮថា ធីសាក់ បាន
ស្លាប់។ជឹងនីបានស្រែកយ៉ាងខ្លាំង



បងស្រី, ពួកយើងត្រូវតែសងសឹក! ពិតជាមិនអាចទ្រាំតទៅទៀតទេ! ” ជឹងចាក់ បាននិយាយទាំងទឹកភ្នែកនឹងក្តុកក្តួល។ ”តោះ ត្រូវធ្វើផែនការដែលគ្រោងជាមួយធីសាកឱ្យបានសម្រេច។ ត្រូវដេញសត្រូវចេញពីប្រទេសយើង ទើបវិញ្ញាណរបស់លោកប្ដីនៅឋានសួគ៌ស្ងប់ចិត្ត។!”



ជំនួសឱ្យ ធីសាកជឹងចាក់បានក្លាយជា
មេដឹកនាំនៃប្រជាជនណាំបៀត។ ជឹង
ចាក់បានបញ្ចុះបញ្ចូលប្រជាជនដែល
ភ័យខ្លាច។ ប្រជាជន រំជួលចិត្ត និង
បានចូលរួមកម្លាំងម្តងទៀតហើយ
កងកម្លាំងបានរីកធំនិងធំជាងមុន។
វេចនដែលត្រូវបានគេហៅថា "ស្ត្រីដ៏
ឆ្នើម" នៅក្នុងទីក្រុងជិតនោះក៏បានមក
ចូលរួមផងដែរ។ នៅទីបំផុតបន្ទាប់ពី
ការរៀបចំទាំងរួចស្រេចដល់ពេលត្រៀម
ចេញធ្វើសង្គ្រាម, ទាហានម្នាក់បានទៅ
សួរជឹងចាក់។ "មេទ័ព, ធីសាក់ បាន
ស្លាប់ទៅហើយ តើយើងទាំងអស់គ្នាគួរ
ចេញដោយឈុតកាន់ទុក្ខមែនទេ?"



មិនមែនទេ! យើងត្រូវពាក់អាវសឹក របស់យើង! ការយកប្រទេសជាតិ មកគឺជារឿងចំបង។ តោះបង្ហាញឱ្យ ទ័ពសត្រូវឃើញពីអំណាចរបស់យើង! ” ជឹងចាក់បាននិយាយ ——————— ——— ជឹងចាក់បានដោះសំលៀក បំពាក់ កាន់ទុក្ខនិងផ្លាស់ប្តូរទៅជាអាវ សឹក ជឹងនីបានឡើងទៅខ្នងដំរីជាមួយ បងស្រីដែលនៅពីខាងមុខគេ។

សម្លេង បូ ... បូ ... បូ ... បូបូ បាន បន្លឺឡើង គ្រប់ទិសទី។ វាគឺជាសញ្ញា វាយប្រហាររបស់កងទ័ពណាំបៀត។ បងប្អូនស្រីជឹងបានវាយប្រហារ ប្រាសាទ ឡីឡាវ ដែលជាទីតាំងស៊ូឌីង



ដោយភាពក្លាហាន ។ ប្រាសាទត្រូវបានកម្ទេចភ្លាមៗ —————————
- បងប្អូនស្រីជឹងនិងប្រជាជនបានរកឃើញឡើងវិញនូវប្រសាទចំនួន 65 ដែលដណ្តើមយកទៅ ត្រឡប់មកវិញក្នុងមួយប៉ព្រិចភ្នែក។ ទាហានរបស់ប្រទេសហាន់ចោលគ្រប់យ៉ាងហើយរត់យកតែខ្លួនយ៉ាងប្រញាប់។ ស៊ូឌីង ដែលភិតភ័យទៅនិងទាហានវៀតណាមនិងបងប្អូនត្រកូលជឹងបានកាត់សក់ក្លែងបន្លំខ្លួនធ្វើជាទាសករហើយរត់គេចខ្លួនទៅប្រទេសខ្លួនវិញ។

ការបះបោររបស់បងប្អូនស្រីជឹងគឺទទួលបានជោគជ័យយ៉ាងខ្លាំង។



ណាំបៀតបានសុខសន្តិភាពក្រោយពី
ការគ្រប់គ្រងរបស់ប្រទេសហាន់
។ មនុស្សម្នាបានអបអរសាទរ
ជាខ្លាំងហើយបានលើក ជឹងចាក់
ជាព្រះមហាក្សត្រ។ ជឹងចាក់បាន
សាងសង់រាជវាំងមួយឈ្មោះ   កូវ៉ា
យ   ដើម្បីកសាងភាពអស្ចារ្យរបស់
ប្រទេសនិង គ្រប់គ្រងប្រជាជនឱ្យ
បានល្អ។ ជឹងនី បានបណ្តុះបណ្តាល
ពួកឧត្តមសេនីយ៍និងទាហាន ហើយ
បានការពារប្រទេសខ្លាំងក្លាផងដែរ។

.

ប្រជាជនរស់នៅដោយសុភមង្គលក្នុង

ការធ្វើកសិកម្មដោយសុខសន្តិភាព។





ប៉ុន្តែសន្តិភាពមិនមានរយៈពេលយូរទេ។

ស្តេចក្វាងមូចេនៃប្រទេសហាន់បានហៅការបះបោររបស់បងប្អូនស្រីជឹងថាជាការបះបោរដ៏អស្ចារ្យហើយបានរៀបចំបេសកកម្មទ្រង់ទ្រាយធំមួយ។

គាត់បានបញ្ជូនកងទ័ពដ៏ធំមួយទៅភាគខាងត្បូងនៃទីក្រុងជាមួយឧត្តមសេនីយ៍ម៉ារ៉ុន។ វាគឺជាកងទ័ពដ៏មានឥទ្ធិពលខ្លាំងរាប់រយដងបើធៀបទៅនិងចំនួនសរុបនៃកងទ័ពរបស់ប្រទេសណាំបៀត។

ប្រជាជន ណាំបៀត មានសេចក្តី



ក្លាហានប៉ុន្តែពួកគេមិនអាចកម្ចាត់កងទ័ពហាន់ដែលមានអំណាចយោធាច្រើនដែលមានបំពាក់ដោយអាវុធល្អៗផងដែរ។

កំលាំងចាប់ផ្តើមស្រុតចុះបន្តិចម្តងៗ មនុស្សនិងទាហានជាច្រើននាក់បានបាត់បង់ជីវិត។ ————————

បងប្អូនស្រីទាំំងពីរសំរេចចិត្តដកថយដោយមិនអាចតទល់ពីការវាយប្រហារដ៏ខ្លាំងក្លារបស់ប្រទេសហាន់បាន។ បន្ទាប់មកបាននាំទាហានទៅលាក់ខ្លួននៅក្នុងព្រៃភាគខាងជើងដែលនៅឆ្ងាយពីតំបន់មេលីង។ អស់រយៈពេលជាងមួយឆ្នាំមកម៉ាវ៉ុនបានបន្តព្យាយាម



ក្នុងការដេញតាមបងប្អូនស្រីត្រកូលជឹង ។ ប្រជាជននៅណាំបៀតត្រូវបានវាយប្រហារឥតឈប់ឈរដោយកងទ័ពហាន់ហើយបានរងការខូចខាតយ៉ាងខ្លាំង។ មេបញ្ជាការចាញ់នៅក្នុងសង្គ្រាមបាននាំទាហានរបស់ពួកគេត្រឡប់ទៅស្រុកកំណើតវិញ។

គេបានបោះបង់ការងើបបះបោរ។—
——————————- បងប្អូនស្រីជឹងមិនបានលះបង់ ក្នុងការតបតនឹងកងកម្លាំងសត្រូវឡើយ។

ថ្វីបើកងទ័ពមានកង្វះក៏ដោយក៏នៅតែបន្តប្រយុទ្ធយ៉ាងស្វិតស្វាញប្រឆាំងនឹងកងកម្លាំងសត្រូវ។



កងទ័ពហាន់វាយប្រហាររឹតតែខ្លាំងក្លាឡើង
ទីបំផុតដំរីរបស់បងប្អូនស្រីជឹងបានដួលរហើយបានងាប់។



កំលាំងរបស់ទាហានបានដួលរលំ,
ទីបំផុតបងប្អូនស្រីជឹងបានចាញ់ការ
ប្រយុទ្ធ។ បងប្អូនស្រីជឹងបានឈរ
នៅមុខទន្លេជាមួយគ្នា។ ”បងស្រី, តើ
ពេលនេះពួកយើងត្រូវធ្វើបែបណា?
ប្រជាជនជាច្រើន កំពុងរងគ្រោះ។
មើលមិនឃើញផ្លូវចេញឡើយ ជឹងនី
និយាយទាំងទឹកភ្នែក។ កុំយំ ពេលនេះ
ពួកយើងមិនអាចធ្វើអ្វីបានទៀតទេ!
តែក៏មិនត្រូវអោយសត្រូវចាប់បាន
នោះដែរ! មិនត្រូវធ្វើជាទាសកររបស់
ពួកឡើយ ជឹងចាក បានចាប់ដៃ
របស់ប្អូនហើយបាននិយាយដូច្នេះ
ជឹងនីបានងក់ក្បាលនៅពេលនាង



មើលទៅបងស្រីនាង។ ————
———— បងប្អូនស្រីជឹងទាំងពី
បានចាប់ដៃគ្នាហើយបានទំលាក់
ខ្លួនទៅក្នុងទន្លេ។ វាជាការបញ្ចប់ដ៏
ក្រៀមក្រំនៃអ្នក ទាំងពីរ។ ចាប់តាំងពី
ពេលនោះមកវៀតណាមស្ថិតនៅ
ក្រោមការគ្រប់គ្រងរបស់ចិនអស់
រយៈពេលជាយូរមកហើយ។ ប៉ុន្តែ
ប្រជាជនវៀតណាមតែងតែមានភាព
មុះមុតនៃអារម្មណ៍បងប្អូនស្រីជឹង
នៅក្នុងចិត្តរបស់ពួកគេ។ ពួកគេបាន
ក្លាយជាវីរបុរសជនជាតិភាគតិចដ៏គួរ
ឱ្យគោរពរបស់វៀតណាម។ បងប្អូន
ស្រីជឹងបានបង្ហាញក្ដីស្រឡាញ់នៃ



ប្រទេសនិងកម្លាំងរបស់ស្ត្រីតាមរយៈ
ជីវិតក្លាហានរបស់ពួកគេ។ នៅទីក្រុង
ហូជីមិញប្រទេសវៀតណាមមានផ្លូវ
មួយហៅថា ហាយបាជឹង ដែល
គោរពដល់បងប្អូនស្រីជឹង។ .សូម្បីតែ
ពេលនេះកូនចៅនៃប្រទេសវៀតណាម
កំពុងតែធំឡើងជាមួយគំរូដ៏មុតមាំរបស់
បងប្អូនស្រីទាំងពីរ។


Vietnam


Vietnam

[illegible]



រហូតមកទល់ពេលនេះអ្នកវិទ្យាសា
ស្ត្របានរុករកចំណេះដឹង,ប្រាជ្ញានិង
បច្ចេកវិទ្យាទំនើបតែមិនអាចរកឃើញ
ភពផ្សេងដែលមនុស្សរស់នៅបាន
ដូច ភពផែនដី ឡើយ។តែមនុស្ស
ទាំងនោះមិនបានឈប់រកភពផ្សេង
ដែលមានជីវិតរស់នៅដូចទៅនិង
ភពផែនដីនុះឡើយ។ គ្មាននណា,និង
គ្មានក្បួនណាដែលអាចរាប់ផ្កាយ
ជាច្រើននៃភពនិមួយៗឡើយ។តែភព
ដែលមនុស្សរស់នៅបានគឺភពផែនដី
តែមួយគត់, អស្ចារ្យបំផុត
ពិតណាស់អារម្មណ៍រំជួលចិត្តនូវ
ពេលដែលបានដឹងនិង។ពិសេស



នៅពេលបានធ្វើការជាមួយនារីប្រទេសផ្សេងៗនៅជុំវិញពិភពលោកដែលមកប្រទេសកូរ៉ឹតតែទទួលអារម្មណ៍រំជួលចិត្តបំផុត។ភពផែនដីតែមួយទោះយើងជាជនជាតិណាក្តីតែជា គ្រួសារផែនដី ។ គ្រួសារត្រូវទុកចិត្តគ្នា,ពឹងផ្អែកលើគ្នា,និងជួយគ្នាទៅវិញទៅមក។ គ្រួសារគឺអោបមុនគេ, សើចដាក់មុនគេ,និងលះបង់អោយមុនគេ។ គ្រួសារគឺរួមទុកជាមួយគ្នា,ជំនះការលំបាកជាមួយគ្នា,ត្រូវដើរទៅជាមួយគ្នា។

ខ្ញុំកោតសរសើរដល់អស់អ្នកដែលបានសរសេរស្នាដៃដ៏អស្ចារ្យតាមរយៈ



ការងារសៀវភៅកុមារ”រួមទាំងគ្នា រួមទាំងអស់គ្នា”។ដោយសារតែអ្នកចូលរួមទាំងអស់នោះសុទ្ធតែត្រូវចិញ្ចឹម បីបាច់កូន,ត្រូវធ្វើកិច្ចការផ្ទះ,មើលថែបម្រើរមនុស្សចាស់ក្នុងផ្ទះ,និងធ្វើការងារជាដើមទោះបីជាមានការនឿយហត់យ៉ាងណាក្តីក៏បានបញ្ចប់កាងារបានជោគជយ័។ពិតជាមិនងាយស្រួលឡើយសំរាប់ការសរសេរជាភាសាកូរ៉េសំរាប់អ្នកមិនទាន់ច្បាស់ទៅនិងភាសារនៅឡើយ។ យ៉ាងណាក្តីការសរសេរបង្កប់ឥទ្ធិពលដែលមិនអាចប្រៀបទៅនិងការនិយាយរាប់រយដង។ ឥទ្ធិពលបង្ហាញអោយឃើញច្បាស់នៅចិត្តគំនិត



ឥទ្ធិពលនៃសមាសសភាពក្នុងការ
ប្រាស្រ័យទាក់ទងជាមួយអ្នកដ៏ទៃ
ឥទ្ធិពលក្នុងការអប់រំកូនអោយបាន
ល្អ មានឥទ្ធិពលទាំងអស់នេះ ខ្ញុំសូម
ជំរុញឱ្យគម្រោងនេះកើតមានឡើង
រឹតតែច្រើន,ដែលផ្តល់មោទនភាពនិង
ក្តីសង្ឃឹមដល់ស្រ្តីចំណាកស្រុកជាច្រើន
និងគ្រួសាររបស់ពួកគេ។ អ្នកនិពន្ធ,ណ្វា
ក៉្យងស៊ីល

서울특별시
SEOUL METROPOLITAN GOVERNMENT

The Asia Foundation
Improving Lives, Expanding Opportunities

MoneyGram Foundation

Brought to you by

The Asia Foundation

Let's Read! is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia. booksforasia.org

To read more books like this and get further information about this book, visit letsreadasia.org

Original Story
□□ □ □□□ □□, Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2019. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/

Contributing translators: Nasema Zeerak